គជអប
NCDD

# ក្របខណ្ឌគណនេយ្យភាពសង្គម

World Vision

## សិទ្ធិប្រជាពលរដ្ឋទទួលបានពី៖

### ៣. សាលាឃុំ

- ក្រុមប្រឹក្សាត្រូវជ្រើសរើសដោយប្រជាពលរដ្ឋ ក្នុងរយៈពេល៥ឆ្នាំម្តង
- ត្រូវស្តាប់យោបល់ប្រជាពលរដ្ឋ
- ត្រូវអញ្ជើញប្រជាពលរដ្ឋប្រជុំ
- ប្រជាពលរដ្ឋអាចសួរក្រុមប្រឹក្សា អំពីសេវា និងគម្រោងនានាបាន
- ផ្តល់សេវាជូនប្រជាពលរដ្ឋ
- ផ្សព្វផ្សាយព័ត៌មាន

### ១. សាលារៀន

- ចូលរៀនដោយឥតគិតថ្លៃរហូតចប់ថ្នាក់ទី៩
- គ្រូម្នាក់សម្រាប់សិស្ស ៣៥-៤០នាក់ក្នុង១ថ្នាក់
- បង្រៀនឲ្យបាន ២១១ថ្ងៃ ក្នុង១ឆ្នាំ
- សៀវភៅ ៣-៥ក្បាល សម្រាប់សិស្សម្នាក់
- មានបង្គន់អនាម័យសម្រាប់សិស្សស្រី និងសិស្សប្រុស
- ជួយសិស្សរៀនសូត្រ ដោយស្មើៗគ្នា ស្រឡាញ់ស្មើៗគ្នា មិនទាមទារបង់ប្រាក់ក្រៅ...

### ២. មណ្ឌលសុខភាព

- ត្រូវបានផ្តល់សេវាដោយស្មើភាពគ្នា
- បង្ហាញជូនពីសេវាសុខភាព
- ជួយពន្យល់អំពីបញ្ហាសុខភាព
- បង់ប្រាក់តាមតារាងតម្លៃ
- រក្សាការសម្ងាត់របស់អ្នកជំងឺ ជាពិសេសស្ត្រី
- មានការយល់ព្រម និងទទួលយោបល់ត្រឡប់




### ថវិកា និងការអនុវត្តការងាររបស់សាលា

សាលារៀនត្រូវបិទផ្សាយព័ត៌មាននៅប្រឡោះចំហទាំង៤៖

1. ចំណូលរបស់សាលារៀន
2. ចំណាយរបស់សាលារៀន
3. ការបំពេញការងារ
   - ចុះឈ្មោះចូលរៀនឥតគិតថ្លៃ
   - មានគ្រូបំពេញគ្រប់គ្រាន់
   - បង្រៀនបាន ២១១ថ្ងៃ ក្នុង១ឆ្នាំ
4. ការបំពេញការងារ
   - ផ្តល់សៀវភៅ ៣-៥ក្បាល
   - អត្រាប្រឡងជាប់ខ្ពស់
   - អត្រាសិស្សរៀនចប់ថ្នាក់ទី៦

### ស្តង់ដារការងារ នៅមណ្ឌលសុខភាព

- មានបុគ្គលិក ពី ៨-១១នាក់
- ត្រូវមានវេនប្រចាំការ ២៤ ម៉ោង
- ត្រូវទទួលថ្នាំ ១២ដង ក្នុង១ឆ្នាំ
- មានបង្គន់ដាច់ដោយឡែក
- ប្រជុំគណៈកម្មការ ១២ដង ក្នុង១ឆ្នាំ
- ត្រូវបិទផ្សាយព័ត៌មានជាសាធារណៈ

### ថវិកា និងការអនុវត្តការងារមណ្ឌលសុខភាព

មណ្ឌលសុខភាពត្រូវបិទផ្សាយព័ត៌មាននៅប្រឡោះចំហទាំង៤៖

1. ចំណូលរបស់មណ្ឌលសុខភាព
2. ចំណាយរបស់មណ្ឌលសុខភាព
3. លទ្ធផលបំពេញការងារ
   - មានបុគ្គលិកគ្រប់គ្រាន់
   - វេនប្រចាំការ ២៤ម៉ោង
   - ទទួលថ្នាំ ១២ដង ក្នុង១ឆ្នាំ
4. លទ្ធផលបំពេញការងារ
   - ស្ត្រីមកពិនិត្យផ្ទៃពោះ ៤ដង
   - ស្ត្រីមកសម្រាលកូន
   - ផ្តល់វ៉ាក់សាំងដល់កុមារ

### ការអនុវត្តការងាររបស់ឃុំ

សាលាឃុំត្រូវបិទនៅតាមប្រឡោះ ចំហទាំងពីរ ដែលបង្ហាញអំពីការបំពេញការងារ របស់ឃុំនីមួយៗ៖

1. ថាតើឃុំមានបានពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋដែរឬទេ?
2. បានប្រជុំក្រុមប្រឹក្សាឬទេ?
3. បានចេញលិខិតនានា ក្នុងរង្វង់៣ថ្ងៃបន្ទាប់ពីទទួលបានឯកសារបញ្ជាក់គ្រប់គ្រាន់ដែរឬទេ?
4. បានផ្សព្វផ្សាយព័ត៌មានជាសាធារណៈដែរឬទេ?
5. បានចុះតាមដានការអនុវត្តគម្រោងដែរឬទេ?

### ថវិកាឃុំ

សាលាឃុំត្រូវបិទផ្សាយព័ត៌មាននៅតាមប្រឡោះ ចំហទាំង៣៖

1. ចំណូលរបស់ឃុំ
2. ចំណាយរបស់ឃុំ
3. ការប្រើប្រាស់ថវិកា (គម្រោងនីមួយៗ)



## វដ្តប្រចាំឆ្នាំ នៃការអនុវត្តក្របខណ្ឌគណនេយ្យភាពសង្គម

